ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៥៤២០ មស.នក

ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម លោកជំទាវ លោក លោកស្រី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ** : ស្តីពីការរំកិលអាយុឱ្យចូលនិវត្តន៍ដល់អាយុ ៦០(ហុកសិប)ឆ្នាំ សម្រាប់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**យោង** :
- ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម លោកជំទាវ លោក លោកស្រី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេត្តាជ្រាបថា អនុលោមតាមមាត្រា២៦នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម មន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាទោះបីជាស្ថិតក្នុងប្រភេទក្របខណ្ឌណាមួយក៏ដោយត្រូវបម្រើការងាររហូតដល់អាយុ៦០(ហុកសិប)ឆ្នាំទើបរៀបចំដាក់ឱ្យចូលនិវត្តន៍តាមនីតិវិធីជាធរមាន។ អនុលោមតាមមាត្រា១០៧នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ចែងថា «ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់» ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩នេះតទៅក្រសួងមុខងារសាធារណៈនឹងរក្សាទុកមន្ត្រីរាជការស៊ីវិលដែលមានប្រភេទក្របខណ្ឌ **ខ** និង **គ** ឱ្យបម្រើការងារបន្តទៀតរហូតដល់ អាយុ ៦០ (ហុកសិប)ឆ្នាំ។

ដោយឡែកចំពោះមន្ត្រីរាជការស៊ីវិលប្រភេទក្របខណ្ឌ **ខ** **និង** **គ** ដែលបានរៀបចំដាក់ឱ្យចូលនិវត្តន៍ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩កន្លងមក ហើយទទួលបានការផ្តល់ជូនប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់មុនពេលចូលនិវត្តន៍ចំនួន ៨(ប្រាំបី)ខែនៃបៀវត្សមូលដ្ឋានចុងក្រោយរួចរាល់ហើយនោះ ក្រសួងមុខងារសាធារណៈសូមស្នើឱ្យសាមីខ្លួនបង្វែរថវិកាទាំងនោះចូលថវិការដ្ឋវិញនិងនៅបន្តបម្រើការងារក្នុងក្របខណ្ឌរបស់ខ្លួនរហូតដល់អាយុ៦០(ហុកសិប)ឆ្នាំ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម លោកជំទាវ លោក លោកស្រីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេត្តាជ្រាបនិងទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ពេជ្រ ម៉ុនធិន

**ចម្លងជូន:**
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត "ដើម្បីសហការអនុវត្តន៍"
- ឯកសារ កាលប្បវត្តិ

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh